00171399

D54/IV

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux Cambodgiens

ជាការចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME

ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
14 / 03 / 2008

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

Declassified to Public
12 April 2013

ភ្នំពេញថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨

ORIGINAL DOCUMENT
RECEIVED ON 14 MARCH 2008
AT 14:25
BY UCH ARUN
COURT OFFICER

ជូនចំពោះលោក **បុន អារុណា**

យើង សូមជម្រាមជូនលោកជ្រាបថា យើងបានទទួលលិខិតរបស់លោកចុះថ្ងៃទី **១៧** ខែមីនា ឆ្នាំ២០០៨ ដែលរំលឹកឡើងវិញអំពីសំណើរបស់លោកចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ ឲ្យមានការធ្វើកោសល្យវិច័យលើកូនក្តីរបស់លោក លោក ន្ឈួន ជា ។

ជាបឋម យើងសូមបញ្ជាក់ជូនលោកថា យើង មិនបានភ្លេចអំពីសំណើរបស់លោកទេ ប៉ុន្តែបើផ្អែកតាមលិខិតរបស់លោកថ្មីៗនេះ យើង អាចបញ្ជាក់បានដូចខាងក្រោម:

១) បញ្ហាភាពសមស្របរបស់កូនក្តីលោកសម្រាប់ការកាត់ទោសនោះ មិនអាចលើកឡើងនៅដំណាក់កាលនេះទេ ដោយសារថាការបញ្ជូនកូនក្តីរបស់លោកទៅកាត់ទោស មិនមែនជាបញ្ហាដែលត្រូវលើកឡើងនៅពេលនេះនោះទេ។

២) ដូចគ្នាដែរ ភាពសមស្របនៃកូនក្តីលោក ក្នុងការចូលរួមក្នុងកិច្ចការងារស៊ើបអង្កេតវិញ ក៏មិនអាចលើកឡើងនាពេលនេះដែរ ដោយសារនៅពេលនេះ កូនក្តីរបស់លោក បានបដិសេធមិនឲ្យសួរចម្លើយទេ។

៣) លើសពីនេះទៀត ការលើកឡើងអំពីករណីដែលថាកូនក្តីរបស់លោកចាំបាច់ត្រូវមានសុខភាពរឹងមាំដើម្បីអាចពិភាក្សាផ្តល់ព័ត៌មានជូនមេធាវីនោះ មិនអាចជាអំណះអំណាងដើម្បីឲ្យមានការធ្វើកោសល្យវិច័យនោះទេ។ លោក មិនបានលើកឡើងនូវអំណះអំណាងណាមួយទាល់តែសោះដែលអាចចង្អុលបង្ហាញថា បញ្ហានេះកំពុងតែកើតមានឡើង។ យើង កត់សំគាល់ថា កូនក្តីរបស់លោក ត្រូវបានពិនិត្យសុខភាពយ៉ាងទៀងទាត់ (នៅពេលថ្មីៗបំផុតគឺកាលសប្តាហ៍មុន) ហើយ មិនមានវេជ្ជបណ្ឌិតណាម្នាក់ បានលើកឡើងពីបញ្ហាណាមួយគួរឲ្យកត់សំគាល់នោះទេ។

ដូចបានជម្រាបជូនខាងលើ យើងនឹងសម្រេចអំពីសំណើរបស់លោកក្នុងពេលឆាប់ៗសមស្របតាមបទប្បញ្ញត្តិនៃវិធាន ៣១ វិធាន ៣២ និងវិធាន ៥៥.១០ នៃវិធានផ្ទៃក្នុង។

សូមលោកទទួលនូវការរាប់អានអំពីយើង។

MARCEL Lemonde